# ប្រព័ន្ធកសិកម្មចម្រុះ រវាងការចិញ្ចឹមគោ មាន់ ការដាំដំឡូងមី ដំឡូងដៃខ្លា សណ្តែកគួរ និងត្រសក់

## ១. និយមន័យ

ប្រព័ន្ធកសិកម្មចម្រុះ **រវាងការចិញ្ចឹមគោ មាន់ ការដាំដំឡូងមី ដំឡូងដៃខ្លា សណ្តែក គួរ និងត្រសក់** គឺជាការធ្វើកសិកម្មច្រើនប្រភេទ ដែលដាំលើផ្ទៃដីជុំវិញផ្ទះ និងចម្រុះគ្នា ទៅតាមទំហំដីតូចធំ នៅតាមគេហដ្ឋានរបស់កសិករ។ ប្រព័ន្ធនេះបានដើរតួរយ៉ាងសំខាន់ និងបំពេញមុខងារឲ្យគ្នាទៅវិញទៅមកជាប្រចាំ។ ការចិញ្ចឹមគោ និងមាន់ គឺយើងអាចប្រមូលលាមក និងសម្រាមបង្កើតបានជាជីសម្រាប់ដាក់ដំណាំដំឡូង

សណ្តែកគួរ ត្រសក់ និងបង្កើនគុណភាពដីកុំឲ្យរឹង និងការពារការបាត់បង់ ជីវសាស្រ្តក្នុងដី។ ចំណែកការដាំដំឡូងមី ដំឡូងដៃខ្លា ត្រសក់ និងសណ្តែកគួរ វាអាចធ្វើជាំណើមាន់ គោ និងធ្វើឲ្យដីមានអន្តរអំពើជាមួយដំណាំ។

## ២. ការរៀបចំប្លង់

តាមរយៈការសិក្សា និងការចុះសង្កេតជាមួយកសិករឃើញថា ការអនុវត្តន៍ប្រព័ន្ធកសិកម្មចម្រុះបែបនេះមានប្រមាណ ១០ ភាគរយដែលអនុវត្តន៍ប្រព័ន្ធកសិកម្មបែបនេះ។ ជាទូទៅនៅក្នុងភូមិមាន ១០៦ គ្រួសារ ហើយមានគ្រួសារប្រមាណ ១០ គ្រួសារដែលបានអនុវត្តន៍ប្រព័ន្ធកសិកម្មបែបនេះ។ ធាតុសំខាន់នៃប្រព័ន្ធនេះរួមមាន ការចិញ្ចឹមសត្វ ឈើហូបផ្លែ ដំណាំ និងការដាំបន្លែ និងជាពិសេសប្រព័ន្ធទឹក។

- ទំហំដីលំនៅដ្ឋានមានចាប់ពី ៣០០ ម៉ែត្រការ៉េឡើងទៅ រហូតដល់ដល់ ២ ហិចតាដែលបានអនុវត្តន៍ប្រព័ន្ធកសិកម្មបែបនេះ។ ពួកគាត់បានអនុត្តន៍ប្រព័ន្ធកសិកម្មបែបនេះ ដើម្បីផ្គត់ផ្គង់ដល់ជីវភាពក្នុងគ្រួសារ និងលក់ទៅទីផ្សារខាងក្រៅ

- មាន់ មានចាប់ពី មេ ៣ក្បាល និងបា ១ក្បាល ឡើងទៅ ដោយចិញ្ចឹមបែបលក្ខណៈប្រពៃណី ដោយប្រើពូជក្នុងស្រុក ហើយជាន់ឈាមគ្នា បណ្តាលឲ្យមាន់មានលកខណៈធំធាត់យឺត និងសំបូរកើតជំងឺច្រើនដូចជា អុត អាសន្នរោគ និងញូកាស ដោយមិនបានប្រើប្រាស់វ៉ាក់សាំង និងថ្នាំព្យាបាលការ

  ពារ។ ការផ្តល់ចំណីវិញគឺបាចអង្ករ រីស្រូវ និងការប្រលែងពាសវាលពាសកាល រកស៊ីដោយខ្លួនវា។ ការការចីញ្ចឹមមាន់របស់ពួកគាត់ គឺគ្រាន់តែបានធ្វើជាម្ហូបអាហារ និងលក់បានតិចតួច ដោយចំណាយពេលរហូត ៦ ទៅ ៦ ខែ ក្នុងការចិញ្ចឹមមាន់។



- គោ គេចាប់ចិញ្ចឹមចាប់ពី ២ក្បាល រហូតដល់ ១៥ ក្បាល ដោយចិញ្ចឹមគោមានទីផ្សារល្អនៅតំបន់នេះមានតំលៃខ្ពស់គួរសម អាចលក់ និងជួយផ្គត់ផ្គង់ដល់ជីវភាពក្នុងគ្រួសារ ហើយជាពិសេសលាមកវាអាចធ្វើជាជីដាក់ដំណាំផ្សេងៗ និងកាត់បន្ថយការទិញជីគីមីផងដែរ

- ដំឡូងមី មានផ្ទៃដីចាប់ពី ២០០ ម៉ែត្រការ៉េឡើងទៅរហូតដល់ ៥០០ ម៉ែត្រការ៉េ ការដាំដំឡូងមីវាជាផ្នែកមួយសម្រាប់ធ្វើជាអាហារសម្រាប់សត្វ មនុស្ស និងអាចលក់ទៅលើទីផ្សារក្នុងតបន់ និងជាពិសេសដំណាំងាយស្រួលដាំ ធន់នឹងភាពរាំងស្ងួត ត្រូវការទឹកតិច



- ដំឡូងដៃខ្លា មានផ្ទៃដីចាប់ពី ២០០ ម៉ែត្រការ៉េឡើងទៅរហូតដល់ ១០០០ ម៉ែត្រការ៉េ ការដាំដំឡូងដៃខ្លាវាជាផ្នែកមួយសម្រាប់ធ្វើជាអាហារសម្រាប់សត្វមនុស្ស និងអាចលក់ទៅលើទីផ្សារតម្លៃខ្ពស់ក្នុងតបន់ (២០០០រៀល/គីឡូក្រាម) និងជាពិសេសដំណាំងាយស្រួលដាំ ធន់នឹងភាពរាំងស្ងួត ត្រូវការទឹកតិច

- សណ្តែកគួរ មានផ្ទៃដីដាំចាប់ពី ៥០ ម៉ែត្រការ៉េ រហូតដល់ ៣០០ ម៉ែត្រការ៉េ គឺគេដាំដើម្បីផ្គត់ផ្គង់សម្រាប់ជាអាហារប្រចាំថ្ងៃ និងបានលក់តិចតួច ដោយសារតំបន់នេះមិនសូវមានទីផ្សារ សណ្តែកគួរ ហើយជាពិសេសសំបូរសត្វល្អិតបំផ្លាញ